# អត្ថបទសង្ខេបការពិនិត្យឡើងវិញនៃស្តង់ដារមូលដ្ឋានពិការភាពក្នុងវិស័យអប់រំ ២០០៥ ឆ្នាំ ២០២០

រដ្ឋាភិបាលនៃប្រទេសអូស្ត្រាលីបានធ្វើការពិនិត្យទៅលើ*ស្តង់ដារមូលដ្ឋានពិការភាពក្នុងវិស័យអប់រំ ២០០៥* (បទដ្ឋាន)ម្តងទៀតក្នុងឆ្នាំ ២០២០។ បទដ្ឋាននេះបានជួយបញ្ជាក់នូវសិទ្ធិនៃសិស្សានុសិស្សពិការភាពក្នុងការចូលរួមកិច្ចសិក្សាបណ្តុះបណ្តាលបានដូចគ្នាទៅនឹងសិស្សដែលគ្មានពិការភាពដែរ។ ក្នុងនោះរួមមានចាប់ពីសាលាមត្តេយ្យ សាលាចំណេះដឹងទូទៅ ការអប់រំវិជ្ជាជីវៈ និងជំនាញបណ្តុះបណ្តាល រហូតដល់ការអប់រំជាន់ខ្ពស់។ បទដ្ឋាននេះបានបកស្រាយពីទំនួលខុសត្រូវដែលមជ្ឈមណ្ឌលអប់រំត្រូវមាន ក្រោមច្បាប់ស្តីពី*ការរើសអើងជនពិការ ១៩៩២*។

នៅក្នុងកិច្ចត្រួតពិនិត្យបទដ្ឋាននាឆ្នាំ២០២០នេះ ក្រុមការងារយើងបានធ្វើការស្វែងយល់ពីសិស្សានុសិស្សពិការភាព រួមទាំងអាណាព្យាបាលរបស់ពួកគាត់ និងក្រុមតស៊ូមតិជនពិការផងដែរ។ មិនតែប៉ុណ្ណោះ យើងក៏បានធ្វើការស្វែងយល់ពីគ្រូបង្រៀនដែលជាអ្នកផ្តល់ចំណេះដឹងអប់រំ ព្រមទាំងមជ្ឈមណ្ឌលអប់រំផងដែរ។ ក្នុងកិច្ចត្រួតពិនិត្យឡើងវិញនៃបទដ្ឋាននេះបានធ្វើការផ្តោតសំខាន់ទៅលើមូលពិសោធន៍សិស្សានុសិស្សពិការភាពរបស់ជនជាតិ Aboriginal និងជនជាតិ Torres Strait Islander ព្រមទាំងក្រុមគ្រួសារ។

ក្រុមការងារយើងបានស្វែងដឹងថាផ្នែកមួយចំនួននៃបទដ្ឋានចាំបាច់ត្រូវធ្វើការកែតម្រូវ ហើយវាក៏ជាការចាំបាច់មួយក្នុងការផ្សព្វផ្សាយបទដ្ឋាននេះឲ្យប្រជាជនកាន់តែច្រើនបានដឹង និងស្វែងយល់។ មិនតែប៉ុណ្ណោះ យើងក៏បានស្វែងដឹងទៀតថាបទដ្ឋាននេះចាំបាច់ត្រូវអនុវត្តឲ្យមានភាពជាក់លាក់តាមស្តង់ដារ។ ផ្នែកទាំងបួនដែលត្រូវធ្វើការកែតម្រូវមានដូចការពណ៌នាខាងក្រោម៖

## ផ្តល់សិទ្ធិអនិភាព និងគាំទ្រដល់សិស្សានុសិស្សពិការភាព ព្រមទាំងក្រុមគ្រួសារ

សិស្សានុសិស្សពិការភាព និងក្រុមគ្រួសារ រួមទាំងអាណាព្យាបាលបានប្រាប់ក្រុមការងារយើងថាមានអតុល្យភាពនៃសិទ្ធិ ឬអំណាចរវាងពួកគាត់ និងមជ្ឈមណ្ឌលអប់រំ។ ពួកគាត់មានអារម្មណ៍ថា វាអាស្រ័យទៅលើពួកគាត់ដែលយល់ច្បាស់ពីច្បាប់ និងប្រព័ន្ធវិស័យអប់រំដែលនាំឲ្យគាត់អាចធ្វើការតស៊ូមតិ ក្នុងការកែតម្រូវដោយសមហេតុផល។

| កែតម្រូវទៅលើ | វិធីកក្នុងការកែតម្រូវ |
|---|---|
| **ព័ត៌មានចំពោះសិស្សានុសិស្សពិការភាព ព្រមទាំងក្រុមគ្រួសារ** | • សហការជាមួយជនពិការក្នុងការអភិវឌ្ឍព័ត៌មានក្នុងបទដ្ឋានដែលបង្ហាញពីសិទ្ធិនៃសិស្សានុសិស្សពិការភាព។<br>• ត្រូវប្រាកដថាព័ត៌មាននេះបានឲ្យសិស្សានុសិស្សពិការភាព និងក្រុមគ្រួសារបានដឹងនាពេលដែលជាប់ពាក់ព័ន្ធក្នុងគ្រាសិក្សា។ |
| **ធានាពីវិធានក្នុងការពិគ្រោះយោបល់ជាមួយសិស្សានុសិស្សពិការភាព និងក្រុមគ្រួសារទៅលើការដោះស្រាយបញ្ហា និងបណ្តឹង** | • កែប្រែបទដ្ឋានក្នុងការបកស្រាយពីវិធីដែលមជ្ឈមណ្ឌលអប់រំគួរធ្វើ៖<br>o ពិគ្រោះជាមួយសិស្សានុសិស្សពិការភាព និងក្រុមគ្រួសារពីកិច្ចគាំទ្រ និងការផ្លាស់ប្តូរដែលពួកគាត់ត្រូវការ<br>o ដោះស្រាយបញ្ហា និងបណ្តឹងដែលទាក់ទងទៅនឹងសិស្សានុសិស្សពិការភាព។ |
| **ការចែករំលែកព័ត៌មានពេលដែលសិស្សានុសិស្សផ្លាស់មណ្ឌលអប់រំ** | • ស្វែងរកវិធីក្នុងការបញ្ជូនព័ត៌មានដែលទាក់ទងនឹងតម្រូវការរបស់សិស្សនោះនាពេលដែលគាត់ផ្លាស់ពីមណ្ឌលសិក្សាមួយទៅមួយ ឬពីមណ្ឌលសិក្សាទៅកាន់ជំនាញបណ្តុះបណ្តាល ឬការអប់រំជាន់ខ្ពស់។ |

## ពង្រឹងនូវចំណេះដឹង និងសមត្ថភាពរបស់អ្នកអប់រំ និងមជ្ឈមណ្ឌលអប់រំ

មនុស្សមួយចំនួនបានអះអាងថា មានអ្នកអប់រំជាច្រើនមិនបានយល់ច្បាស់ពីទំនួលខុសត្រូវខ្លួនដែលស្ថិតក្រោមស្តង់ដាររបស់បទដ្ឋាន ឬមិនមានព័ត៌មានគ្រប់គ្រាន់ដែលចាំបាច់ក្នុងការអនុវត្តបទដ្ឋាននោះ។ សិស្សានុសិស្សពិការភាពនឹងទទួលបានបទពិសោធន៍ល្អប្រសើរនៅពេលដែលអ្នកអប់រំ និងមជ្ឈមណ្ឌលអប់រំរបស់ពួកគាត់យល់ច្បាស់ពីស្តង់ដាររបស់បទដ្ឋាន ហើយអនុវត្តបទដ្ឋាននោះត្រឹមត្រូវទៅតាមស្តង់ដារ។

| កែតម្រូវទៅលើ | វិធីកក្នុងការកែតម្រូវ |
|---|---|
| ព័ត៌មានចំពោះមជ្ឈមណ្ឌលអប់រំ | • អភិវឌ្ឍន៍ព័ត៌មានក្នុងបទដ្ឋានដែលបង្ហាញពីទំនួលខុសត្រូវដែលមជ្ឈមណ្ឌលអប់រំត្រូវមាន។<br>• ផ្តល់បទបង្ហាញល្អៗនៅក្នុងការគាំទ្រសិស្សានុសិស្សពិការភាព។ |
| ការបណ្តុះបណ្តាលចំណេះដឹងពីបទដ្ឋានទៅកាន់អ្នកដឹកនាំ និងគ្រូបង្រៀន | • សាកសួររដ្ឋាភិបាលរដ្ឋ និងទឹកដី ដើម្បីធានាថាអ្នកដឹកនាំ និងគ្រូបង្រៀនបានឆ្លងកាត់វគ្គបណ្តុះបណ្តាលអំពីស្តង់ដារបទដ្ឋានគាំទ្រសិស្សានុសិស្សពិការភាពមុនពេលដែលពួកគាត់ចូលកាន់តំណែង។ |
| បញ្ចូលបទដ្ឋានទៅក្នុងគោលនយោបាយ និងការអនុវត្តអប់រំជាន់ខ្ពស់ | • ធានាថាបទដ្ឋានត្រូវបានចុះបញ្ចូលទៅក្នុងគោលនយោបាយ និងការអនុវត្តជាន់ខ្ពស់របស់មជ្ឈមណ្ឌលអប់រំ។ |

## គណនេយ្យភាពនឹងមានកាន់តែច្រើនសម្រាប់ស្តង់ដារនូវទាំងវិស័យអប់រំ

មនុស្សមួយចំនួនបានអះអាងថា គណនេយ្យភាពដែលធានានូវការអនុវត្តស្តង់ដារបទដ្ឋានចាំបាច់ត្រូវមានការរីកចម្រើនប្រសើរឡើង។ ពួកគាត់ចង់បានព័ត៌មានបន្ថែមអំពីវិធីដែលមជ្ឈមណ្ឌលអប់រំអនុវត្តបទដ្ឋាន។

| កែតម្រូវទៅលើ | វិធីកក្នុងការកែតម្រូវ |
|---|---|
| ធានានូវគោលនយោបាយអប់រំស្របទៅនឹងស្តង់ដារបទដ្ឋាន | • សហការជាមួយនឹងរដ្ឋាភិបាលរដ្ឋ និងទឹកដី ដើម្បីធានាបានថាច្បាប់ និងគោលនយោបាយអប់រំត្រូវបានអនុវត្តស្របទៅតាមស្តង់ដាររបស់បទដ្ឋាន។ |
| កំណែលំអការអប់រំវិជ្ជាជីវៈ និងជំនាញបណ្តុះបណ្តាលសម្រាប់សិស្សានុសិស្សពិការភាព | • សហការជាមួយនឹងរដ្ឋាភិបាលរដ្ឋ និងទឹកដី ដើម្បីពង្រឹង ក៏ដូចជាធ្វើការកែលម្អផ្នែកផ្សេងៗនៃការអប់រំវិជ្ជាជីវៈ និងជំនាញបណ្តុះបណ្តាលសម្រាប់សិស្សានុសិស្សពិការភាព។ |
| ផ្តល់ព័ត៌មានទៅកាន់ទីសាធារណៈកាន់តែច្រើនដែលទាក់ទងនឹងការគាំទ្រសិស្សានុសិស្សពិការភាពរបស់មណ្ឌលអប់រំ | • មជ្ឈមណ្ឌលអប់រំនឹងត្រូវតម្រូវឲ្យដាក់បង្ហាញព័ត៌មានដែលទាក់ទងទៅនឹងសេវាកម្ម និងការគាំទ្រសិស្សានុសិស្សពិការភាពដែលមាន នៅលើគេហទំព័ររបស់ខ្លួន។ |
| ទិន្នន័យ និងការរាយការណ៍អំពីសិស្សានុសិស្សពិការភាព | • សហការជាមួយនឹងរដ្ឋាភិបាលរដ្ឋ និងទឹកដី ដើម្បីអភិវឌ្ឍនូវគោលការណ៍ជាតិ និងការអនុវត្តក្នុងប្រមូលយកទិន្នន័យ ព្រមទាំងរបាយការណ៍ដែលទាក់ទងនឹងការចូលរួមការអប់រំនៃសិស្សានុសិស្សពិការភាព។ |
| ត្រួតពិនិត្យប្រសិទ្ធភាពនៃការអនុវត្តបទដ្ឋាន | • សាកសួររដ្ឋាភិបាលរដ្ឋ និងទឹកដីក្នុងការចូលរួមត្រួតពិនិត្យបញ្ជាក់ពីប្រសិទ្ធភាពនៃការអនុវត្តតាមស្តង់ដារបទដ្ឋាន។ |

# បង្កើនការយល់ដឹង
# និងសមត្ថភាពនៅក្នុងវិស័យអប់រំ
# និងថែទាំកុមារតូច (ECEC)

បច្ចុប្បន្ន បទដ្ឋាននេះមិនទាន់មានការអនុវត្តទៅលើអ្នកផ្តល់ការថែទាំកុមារនៅឡើយទេ

ប៉ុន្តែអ្នកដែលផ្តល់សេវាការថែទាំទាំងនេះក៏ត្រូវតែគោរពតាមច្បាប់ដែលស្តីពីការរើសអើងជនពិការ ១៩៩២ (DDA)ផងដែរ។

យោងតាមច្បាប់ DDA

គឺមានការគាំទ្រខ្លាំងណាស់ដែលអាចធានាបានថាមជ្ឈមណ្ឌលអប់រំ

និងអ្នកផ្តល់សេវាថែទាំ និងអប់រំកុមារយល់ដឹងច្បាស់ពីទំនួលខុសត្រូវរបស់ពួកគេ។

ក្រុមការងារយើងក៏បានស្វែងយល់ទៀតថា ក្រុមគ្រួសារ ព្រមទាំងអ្នកថែទាំត្រូវការយល់ដឹងបន្ថែមពីច្បាប់

DDA ផងដែរ។

| កែតម្រូវទៅលើ | វិធីក្នុងការកែតម្រូវ |
|---|---|
| ព័ត៌មានចំពោះក្រុមគ្រួសារ និងអ្នកថែទាំទាក់ទងពីសិទ្ធិកុមារ | • អភិវឌ្ឍន៍ផលិតផលសម្រាប់ក្រុមគ្រួសារ និងអ្នកថែទាំទាក់ទងនឹងសិទ្ធិរបស់កុមារពិការភាពក្នុង ECEC។ |
| ព័ត៌មានចំពោះអ្នកផ្តល់សេវា ECEC | • សហការជាមួយនឹងរដ្ឋាភិបាលរដ្ឋ និងទឹកដី ដើម្បីអភិវឌ្ឍធនធានសម្រាប់អ្នកផ្តល់សេវា ECEC និងធានាឲ្យបានថាអ្នកដែលផ្តល់សេវានោះបានយល់ និងដឹងច្បាស់ពីច្បាប់ DDA។ |
| ធានាពីគោលនយោបាយ ECEC សមស្របទៅតាមច្បាប់ DDA | • សហការជាមួយនឹងរដ្ឋាភិបាលរដ្ឋ និងទឹកដី ដើម្បីធានាឲ្យបាននូវគ្រប់ប្រការទាំងអស់ដែលអនុវត្តទៅលើអ្នកផ្តល់សេវា ECEC សមស្របទៅតាមច្បាប់ DDA។ |
| ធ្វើការកែប្រែបទដ្ឋាន ដើម្បីដាក់បញ្ចូល ECEC | • កែប្រែបទដ្ឋានក្នុងការដាក់បញ្ចូល ECEC និងពិគ្រោះជាមួយវិស័យ ECEC ពីការកែប្រែ។ |

## ការធ្វើកំណែប្រែ

ចំណុចមួយចំនួននៃការកែប្រែខាងលើនេះ គឺជាចំណុចដែលរដ្ឋាភិបាលប្រទេសអូស្ត្រាលីអាចធ្វើបានដោយខ្លួនឯងផ្ទាល់

ប៉ុន្តែការកែប្រែជាច្រើននឹងត្រូវការការទទួលស្គាល់ និងការសហការគ្នាពីរដ្ឋាភិបាលរដ្ឋ និងទឹកដីទើបអាចធ្វើបាន។ ឯការកែប្រែមួយចំនួនទៀត

ក៏ត្រូវការសហការគ្នារវាងរដ្ឋាភិបាលរដ្ឋ និងទឹកដី និងមជ្ឈដ្ឋានអប់រំក្នុងការកែប្រែ ឬបង្កើតនូវអ្វីដែលថ្មី។

កំណែប្រែនឹងប្រព្រឹត្តិទៅក្រោមជំនួយ និងឲ្យយោបល់ពីជនពិការ។ ក្នុងនោះក៏មានរាប់បញ្ចូលនឹងការសហការជាមួយជនជាតិ និងសហគមន៍ Aboriginal និង

Torres Strait Islander។

ក្រុមការងារយើងនឹងនាំយកនូវព័ត៌ថ្មីៗដែលទាក់ទងទៅនឹងការអភិវឌ្ឍនៃកំណែប្រែទាំងអស់នេះ។

សម្រាប់ព័ត៌មានបន្ថែម  សូមចូលទៅកាន់គេហទំព័រ www.dese.gov.au/disability-standards-education-2005/2020-review-disability-standards-education-2005។